ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ០៥៦ សកបយ

ភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០០០

# ប្រកាស
## ស្តីពី
## កៅអីអង្គុយនៅប៉ុស្តិ៍ការងារ

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩-០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## សំរេច

ប្រការ១.- និយោជក នៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុង មាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំនៅតាមប៉ុស្តិការងារនិមួយៗ ឱ្យមានកៅអីដ៏សមរម្យសំរាប់ប្រើប្រាស់តាមបំណងកម្មករ និយោជិត [illegible]

ប្រការ២.- ទោះក្នុងករណីយ៉ាងណាក៏ដោយ និងទោះបីការងារមិនតម្រូវឱ្យមានសកម្មភាពឬឥរិយាបថអង្គុយក៏ដោយ និយោជកក៏ត្រូវរៀបចំឱ្យមានកៅអីគ្រប់គ្រាន់នៅមិនឆ្ងាយពីប៉ុស្តិការងារ សំរាប់កម្មករនិយោជិត ប្រើប្រាស់នៅពេលចាំបាច់ ។

ប្រការ៣.- បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន អាចមានការបញ្ជាក់ឬកំណត់ ពីការប្រើប្រាស់កៅអីអង្គុយ ។

ប្រការ៤.- អ្នកប្រព្រឹត្តល្មើសនិងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ៥.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- គ្រប់មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- សមាគមនិយោជក "ដើម្បីអនុវត្ត"
- សហភាពសហជីព "ដើម្បីអនុវត្ត"
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ និងឯកសារ